**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ១៩៩០ អ.ក
ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១
**សាលក្រមព្រហ្មទណ្ឌ**
លេខ ៩១ "ផ"
ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០៨:៣០ នាទីព្រឹក ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៩៩០ អ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សាឡេះ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរឥស្លាម មុខរបរ នេសាទ កម្រិតវប្បធម៌ថ្នាក់ទី៣ មានទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] យ៉ើ "រស់" ម្ដាយឈ្មោះ [redacted] ម៉ាស់ "ស្លាប់" ប្រពន្ធឈ្មោះ [redacted] ម៉ារី មានកូន ០១នាក់ ទោសពីមុន -**ធ្លាប់ជាប់ពន្ធនាគារ ២ឆ្នាំ៦ខែ ក្នុងករណីគ្រឿងញៀន**- ជានីតិជន (ក្នុងឃុំ) ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤៨១៧ ដក.បយខ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ។

២-ឈ្មោះ [redacted] សង្ហា ហៅ សីហា ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ថ្នាក់ទី៩ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នភូមិព្រែកក្ដាម២ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សារឿន "ស្លាប់" ម្ដាយឈ្មោះ [redacted] សុវណ្ណ "រស់" ប្រពន្ធឈ្មោះ [redacted] សុភាព មានកូន ០៥នាក់ ទោសពីមុន -**ធ្លាប់ជាប់ពន្ធនាគារ ២ឆ្នាំ៦ខែ ក្នុងករណីគ្រឿងញៀន**- ជានីតិជន (ក្នុងឃុំ) ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤៨១៩ ដក.បយខ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។



Scanned with CamScanner

ជាប់ចោទពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទួលងោក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១១ និង ៥០នាទី បន្ទាប់ពីបានទទួលដំណឹងពីប្រជាពលរដ្ឋ ថាមានករណីពាក់ព័ន្ធនឹងគ្រឿងញៀននៅចំណុចផ្លូវបេតុង ស្ថិតក្នុងភូមិទួលងោក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល ។ ភ្លាមនោះកម្លាំងសមត្ថកិច្ចនៃប៉ុស្តិ៍នគរបាលរដ្ឋបាលកំពង់លួង បានចុះទៅដល់កន្លែងកើតហេតុ ក៏ប្រទះឃើញឈ្មោះ [redacted] សាឡេះ នៅទីនោះគួរឲ្យសង្ស័យ ក៏ហៅមកសាកសួរ និងឆែកឆេរឃើញថ្នាំញៀនចំនួន ០២កញ្ចប់តូច ទើបសមត្ថកិច្ចធ្វើការឃាត់ខ្លួនឈ្មោះ [redacted] សាឡេះ តែម្តង ។ តាមចម្លើយរបស់ឈ្មោះ [redacted] សាឡេះ បានឆ្លើយថា ចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន គឺខ្លួនបានទិញពីឈ្មោះ [redacted] **សង្ហា ហៅ សីហា** ដោយខ្លួនទិញម្តងៗអស់ប្រាក់ចំនួន ១០០,០០០ (ដប់ម៉ឺន) រៀល ដើម្បីយកមកវែចែកទុកលក់បន្ត ។ ក្រោយការសាកសួរឈ្មោះ [redacted] សាឡេះ រួច សមត្ថកិច្ចក៏ចុះទៅធ្វើការឃាត់ខ្លួនឈ្មោះ [redacted] **សង្ហា ហៅ សីហា** បានម្តងទៀត ។ តាមចម្លើយរបស់ឈ្មោះ [redacted] **សង្ហា ហៅ សីហា** បានឆ្លើយថា ខ្លួនពិតជាបានលក់ថ្នាំញៀនឲ្យឈ្មោះ [redacted] **សាឡេះ** ប្រាកដមែន ដោយថ្នាំញៀនដែលខ្លួនលក់ឲ្យនោះ គឺខ្លួនបានទិញពីឈ្មោះ **ហ្សាត ហៅ ឆាត** ភេទប្រុស អាយុ ៣៦ឆ្នាំ រស់នៅភូមិឃ្លាំងស្បែក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល ។

**-បានឃើញ** របាយការណ៍លេខ ០២៨ របក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកពញាឮ ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៨៣៩ **ដកសស** ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **១២៨ ដកសព** ចុះថ្ងៃ២៧ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

**-បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ **១៦២ តក.ព្រទ/២២** ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សាឡេះ** បានឆ្លើយថា៖ ខ្លួនទទួលយកការចោទប្រកាន់ ដោយនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ **សីហា** ក្នុងតម្លៃ ១០ម៉ឺនរៀល រួចយកមកវែចែកជាកញ្ចប់តូចៗ បានចំនួន ០៥កញ្ចប់ ហើយខ្លួនបានលក់បន្តឲ្យគេអស់២កញ្ចប់ តម្លៃ ៣០,០០០ (បីម៉ឺន) រៀល

និងប្រើប្រាស់ខ្លួនឯងអស់១កញ្ចប់ ស្រាប់តែសមត្ថកិច្ចចុះមកឆែកឆេរនិងឃាត់ខ្លួនតែម្តង ។ ឈ្មោះ សីហា ដែលលក់ថ្នាំញៀនឱ្យខ្លួន គឺមានសម្បុរខ្មៅ មិនមែនឈ្មោះ [redacted] សង្ហា ហៅ សីហា ដែលនៅទីនេះទេ ហើយពេលដែលសមត្ថកិច្ចចុះចាប់ឈ្មោះ [redacted] សង្ហា ហៅ សីហា ខ្លួនក៏បានបញ្ជាក់ដែរថា គឺមិនមែនទេ ប៉ុន្តែសមត្ថកិច្ចមិនស្តាប់ ។ ពីមុនខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] សង្ហា ហៅ សីហា បានម្តងនៅខែកុម្ភៈ ឆ្នាំ២០២១ ហើយក្រោយៗមកគឺខ្លួនទិញថ្នាំញៀនពីឈ្មោះ ហ្សាត ។ សំណូមពរ សុំឱ្យតុលាការបន្ធូរបន្ថយទោស ។

-ជនជាប់ចោទឈ្មោះ [redacted] សង្ហា ហៅ សីហា បានឆ្លើយថា៖ ខ្លួនមិនទទួលយកការចោទប្រកាន់ទេ ព្រោះថ្នាំញៀនដែលសមត្ថកិច្ចចាប់បានពីឈ្មោះ [redacted] សាឡេះ គឺមិនមែនជាថ្នាំញៀនដែលទិញពីខ្លួនទេ ។ ពីមុនខ្លួនធ្លាប់លក់ថ្នាំញៀនឱ្យឈ្មោះ [redacted] សាឡេះ បានម្តង ហើយក្រោយពីខ្លួនបានចេញពីពន្ធនាគារមក គឺខ្លួនមិនដែលបានជួប ឬលក់ថ្នាំញៀនឱ្យឈ្មោះ [redacted] សាឡេះ ទៀតទេ ។ សំណូមពរ សុំឱ្យតុលាការសម្រេចលើកលែងចោទប្រកាន់មកលើរូបខ្លួន ។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ជនជាប់ចោទបានព្យាយាមឆ្លើយដោះសារ ដោយជនជាប់ចោទឈ្មោះ [redacted] សាឡេះ បានព្យាយាមទម្លាក់ការទទួលខុសត្រូវឱ្យទៅឈ្មោះ ហ្សាត ហើយជនជាប់ចោទឈ្មោះ [redacted] សង្ហា ហៅ សីហា បានព្យាយាមឆ្លើយដោះសារ ប៉ុន្តែបើពិនិត្យមើលលើសំណុំរឿង គឺមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទទាំងពីរ ហេតុនេះស្នើសុំតម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសក្នុងកម្រិតអតិបរមា ព្រោះជនជាប់ចោទទាំងពីរមិនដឹងពីកំហុសរបស់ខ្លួន ។

-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សង្ហា ហៅ សីហា បានធ្វើការសន្និដ្ឋានថា៖ អង្គហេតុនេះគឺមិនពាក់ព័ន្ធនឹងកូនក្តីខ្លួនទេ ហើយថ្នាំញៀនដែលចាប់បានក៏មិនមែនជារបស់កូនក្តីខ្លួនដែរ មិនតែប៉ុណ្ណោះពេលសមត្ថកិច្ចចាប់ខ្លួនកូនក្តីខ្លួនក៏មិនមានដកហូតបាននូវថ្នាំញៀនដែរ ។ កូនក្តីខ្លួនទើបតែចេញពីពន្ធនាគារបាន ២ខែប៉ុណ្ណោះ ហើយក៏មិនដែលបានជួប ឬលក់ថ្នាំញៀនឱ្យឈ្មោះ [redacted] សាឡេះ ដែរ ។ កូនក្តីខ្លួនបានរាងចាល សំណូមពរសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ ព្រោះកូនក្តីខ្លួនមានបន្ទុកគ្រួសារ មានកូនតូច ម្តាយមានជម្ងឺ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១១ និង ៥០នាទី នៅចំណុចភូមិទួលដោក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] សាឡេះ បានទូរស័ព្ទទៅទិញថ្នាំញៀនប្រភេទ



Scanned with CamScanner

ម៉ាទឹកកកពីឈ្មោះ [redacted] សង្ហា ហៅ សីហា ក្នុងតម្លៃ ១០ម៉ឺនរៀល ហើយឈ្មោះ [redacted] សីហា ហៅ សីហា ក៏បានជិះម៉ូតូម៉ាកនិច ពណ៌សលាយខៀវ យកថ្នាំញៀនមកលក់ឲ្យឈ្មោះ [redacted] សាឡោះ ។ ក្រោយពីទិញរួច ឈ្មោះ [redacted] សាឡោះ បានយកថ្នាំញៀននេះមកវែកជាកញ្ចប់តូចៗ បានចំនួន ០៥កញ្ចប់ ដោយលក់បន្តអស់ចំនួន ០២កញ្ចប់តូចបានប្រាក់ ៣ម៉ឺនរៀល និងប្រើប្រាស់ខ្លួនឯងអស់ ០១កញ្ចប់តូច ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សាឡោះ បានឆ្លើយថា ខ្លួនទទួលយកការចោទប្រកាន់ ដោយនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ សីហា ក្នុងតម្លៃ ១០ម៉ឺនរៀល រួចយកមកវែកជាកញ្ចប់តូចៗ បានចំនួន០៥កញ្ចប់ ហើយខ្លួនបានលក់បន្តឲ្យគេអស់២កញ្ចប់ តម្លៃ ៣០,០០០ (បីម៉ឺន) រៀល និងប្រើប្រាស់ខ្លួនឯងអស់១កញ្ចប់ ស្រាប់តែសមត្ថកិច្ចចុះមកឆែកឆេរនិងឃាត់ខ្លួនតែម្តង ។ ឃើញថា ជនជាប់ចោទរូបនេះបានឆ្លើយសារភាព ហេតុនេះគប្បីតុលាការពិចារណា ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សង្ហា ហៅ សីហា បានឆ្លើយថា ខ្លួនមិនទទួលយកការចោទប្រកាន់ទេ ព្រោះថ្នាំញៀនដែលសមត្ថកិច្ចចាប់បានពីឈ្មោះ [redacted] សាឡោះ គឺមិនមែនជាថ្នាំញៀនដែលទិញពីខ្លួនទេ ។ ពីមុនខ្លួនធ្លាប់លក់ថ្នាំញៀនឲ្យឈ្មោះ [redacted] សាឡោះ បានម្តង ហើយក្រោយពីខ្លួនបានចេញពីពន្ធនាគារមក គឺខ្លួនមិនដែលបានជួប ឬលក់ថ្នាំញៀនឲ្យឈ្មោះ [redacted] សាឡោះ ទៀតទេ ។

តុលាការយល់ឃើញថា ចម្លើយនេះជាចម្លើយដោះសារ ដោយហេតុថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សាឡោះ នៅសមត្ថកិច្ចនិងនៅអយ្យការ បានឆ្លើយដាក់បន្ទុកទៅលើជនជាប់ចោទរូបនេះថា នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនបានទាក់ទងទៅឈ្មោះ [redacted] សង្ហា ហៅ សីហា ដើម្បីទិញថ្នាំញៀន ដោយខ្លួនធ្លាប់ទិញពីឈ្មោះ [redacted] សីហា ចំនួន ០៣ថ្ងៃជាប់ៗគ្នា ក្នុងម្តងៗតម្លៃ ១០ម៉ឺនរៀល ហើយក្រោយមកឈ្មោះ សង្ហា បានជិះម៉ូតូម៉ាកនិច ពណ៌ខៀវ លាយស យកថ្នាំញៀនមកឲ្យខ្លួនរាល់ដង ។ម្យ៉ាងវិញទៀត ក្រៅតែពីការអះអាងដោះបន្ទុកដោយផ្ទាល់មាត់ ជនជាប់ចោទរូបនេះក៏មិនបានបង្ហាញភស្តុតាង ឬសាក្សីណាមួយបញ្ជាក់ឲ្យតុលាការជឿជាក់បានដែរ ។

៤-តាមកំណត់ហេតុទទួលស្គាល់វត្ថុតាង និងកំណត់ហេតុធ្វើតេស្តបឋមនិងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកពញាឮ បានបញ្ជាក់ថា ក្រាមពណ៌សថ្លាចំនួន ០២កញ្ចប់តូច មានទម្ងន់ ០,៣០ក្រាម ជាប្រភេទ មេតំហ្វេតាមីន ពិតជាបានដកហូត និងទទួលស្គាល់ពីជនជាប់ចោទឈ្មោះ [redacted] សាឡោះ ប្រាកដមែន ។

៥-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៩៧ អ.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬ អាយ) គឺមានកម្រិតភាពសុទ្ធ ៧១.៣៣% នៃទម្ងន់សរុប។ ដូច្នេះតាមការគណនាភាពសុទ្ធរបស់មេតំហ្វេតាមីន ដែលចាប់ដកហូតបានគឺ ០,៣០ក្រាមx ៧១.៣៣%=០,២១ក្រាម គប្បីពិចាតុលាការពិចារណា ។



Scanned with CamScanner

៦-តាមរបាយការណ៍លេខ ០២៨/២០២១ របក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកពញាឮ បានសន្និដ្ឋានថា ឈ្មោះ [redacted] សាឡេះ និងឈ្មោះ [redacted] សង្កា ហៅ សីហា ពិតជាបានធ្វើសកម្មភាព ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៧-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ជនជាប់ចោទបានព្យាយាមឆ្លើយដោះសារ ដោយជនជាប់ចោទឈ្មោះ [redacted] សាឡេះ បានព្យាយាមទម្លាក់ការទទួលខុសត្រូវឱ្យទៅឈ្មោះ ហ្វាត ហើយជនជាប់ចោទឈ្មោះ [redacted] សង្កា ហៅ សីហា បានព្យាយាមឆ្លើយដោះសារ ប៉ុន្តែបើពិនិត្យមើលលើសំណុំរឿង គឺមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទទាំងពីរ ហេតុនេះស្នើសុំតម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសក្នុងកម្រិតអតិបរមា ព្រោះជនជាប់ចោទទាំងពីរមិនដឹងពីកំហុសរបស់ខ្លួន គប្បីតុលាការពិចារណា ។

៨-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សង្កា ហៅ សីហា បានធ្វើការសន្និដ្ឋានថា អង្គហេតុនេះគឺមិនពាក់ព័ន្ធនឹងកូនក្តីខ្លួនទេ ហើយថ្នាំញៀនដែលចាប់បានក៏មិនមែនជារបស់កូនក្តីខ្លួនដែរ មិនតែប៉ុណ្ណោះពេលសមត្ថកិច្ចចាប់ខ្លួនកូនក្តីខ្លួនក៏មិនមានដកហូតបាននូវថ្នាំញៀនដែរ ។ កូនក្តីខ្លួនទើបតែចេញពីពន្ធនាគារបាន ២ខែប៉ុណ្ណោះ ហើយក៏មិនដែលបានជួប ឬលក់ថ្នាំញៀនឱ្យឈ្មោះ [redacted] សាឡេះដែរ ។ កូនក្តីខ្លួនបានរាងចាល សំណូមពរសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ ព្រោះកូនក្តីខ្លួនមានបន្ទុកគ្រួសារ មានកូនតូច ម្តាយមានជម្ងឺ ។

តុលាការយល់ឃើញថា ការសន្និដ្ឋាននេះមិនមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុនៃរឿងទេ ហើយម្យ៉ាងទៀត ដោយសារបទល្មើសនេះគឺកំពុងតែកើនឡើងខ្លាំងនាពេលបច្ចុប្បន្ន ហើយបានបង្កភាពចលាចលក្នុងសង្គមយ៉ាងធ្ងន់ធ្ងរ ដែលគប្បីត្រូវអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹង និងមិនគួរមានការបន្ធូរបន្ថយទោសឡើយ ហេតុនេះតុលាការសម្រេចមិនលើកយកការសន្និដ្ឋាននេះមកធ្វើការពិចារណាឡើយ ។

៩-តាមចម្លើយរបស់ជនជាប់ចោទ របាយការណ៍របស់សមត្ថកិច្ច និងភស្តុតាងនានាក្នុងសំណុំរឿង ឃើញថា មានលក្ខណៈស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងអង្គហេតុ ដែលអាចបញ្ជាក់បានថា កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ នៅចំណុចភូមិទួលងោក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] សាឡេះ បានទូរស័ព្ទទៅទិញថ្នាំញៀនប្រភេទម៉ាទឹកកកពីឈ្មោះ [redacted] សង្កា ហៅ សីហា ក្នុងតម្លៃ ១០ម៉ឺនរៀល ហើយឈ្មោះ [redacted] សីហា ហៅ សីហា ក៏បានជិះម៉ូតូម៉ាកនិច ពណ៌សលាយខៀវ យកថ្នាំញៀនមកលក់ឱ្យឈ្មោះ [redacted] សាឡេះ ។ ក្រោយពីទិញរួច ឈ្មោះ [redacted] សាឡេះ បានយកថ្នាំញៀននេះមករំលែកជាកញ្ចប់តូចៗ បានចំនួន ០៥កញ្ចប់ ដោយលក់បន្តអស់ចំនួន ០២កញ្ចប់តូចបានប្រាក់ ៣ម៉ឺនរៀល និងប្រើប្រាស់ខ្លួនឯងអស់ ០១កញ្ចប់តូច ប្រាកដមែន ។

១០-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សាឡេះ និងឈ្មោះ [redacted] សីហា ហៅ សីហា ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិទួលងោក ឃុំ



Scanned with CamScanner

កំពង់លួង ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

១១-វត្ថុចាប់យករួមមាន៖ ម្សៅក្រាមពណ៌សថ្លា ចំនួន ០២កញ្ចប់តូច និងម៉ូតូម៉ាក NEX ពណ៌សលាយខៀវ ពាក់ស្លាកលេខ កំពត 1Q-1046 គប្បីតុលាការសម្រេចរឹបអូសតាមច្បាប់ ។

**ហេតុដូច្នេះសម្រេច**

១-ផ្ដន្ទាទោស៖

ក-ឈ្មោះ [redacted] សាឡេះ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរឥស្លាម (**ក្នុងឃុំ**)

ខ-ឈ្មោះ [redacted] សង្ហា ហៅ សីហា ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ (**ក្នុងឃុំ**)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ **០២ឆ្នាំ ០៦ខែ** និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន **៤,០០០,០០០ (បួនលាន) រៀល** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិទួលងោក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុចាប់យករួមមាន៖ ម្សៅក្រាមពណ៌សថ្លា ចំនួន ០២កញ្ចប់តូច និងម៉ូតូម៉ាក NEX ពណ៌សលាយខៀវ ពាក់ស្លាកលេខ កំពត 1Q-1046 ***ត្រូវរឹបអូស*** ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈ **ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២** ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សាឡេះ** ឈ្មោះ [redacted] **សង្ហា ហៅ សីហា** និងប្រកាសជាសាធារណៈ **ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២** ។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted] |

“**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**”

ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

កណ្ដាល,ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner